**កោះសន្តិភាព** ឆ្នាំទី៤២ លេខ៦៧៣២ ថ្ងៃពុធ ទី១៩ ខែសីហា ឆ្នាំ២០០៩



ក្រុមអ្នករត់ម៉ូតូឌុបនាំគ្នាហែក្បួនសុំរដ្ឋាភិបាលបញ្ចុះតំលៃពន្ធនាំចូល (រូបថត តាសោម)

## ក្បួនម៉ូតូកក្រើកមាត់សមុទ្រអ្នកប្រើប្រាស់ម៉ូតូអំពាវនាវឱ្យមានការបញ្ចុះតំលៃពន្ធដែលមានអត្រាខ្ពស់

ខេត្តព្រះសីហនុ ៖ ការទាមទារឱ្យមានការបញ្ចុះពន្ធម៉ូតូ ដោយសំអាងថា មានអត្រាខ្ពស់ពេកបានក្លាយជាសំរែកចេញពីក្រុមអ្នករត់ម៉ូតូឌុប និងមានម៉ូតូប្រមាណជាង៥០០គ្រឿង ដែលបានប្រមូលផ្តុំគ្នាធ្វើការហែជាក្បួនតាមផ្លូវនានាក្នុងក្រុងព្រះសីហនុ ។ ការដង្ហែជាក្បួនម៉ូតូនេះបានចាប់ផ្តើមតាំងពី រសៀលថ្ងៃទី១៧ សីហា ហើយកាន់តែគគ្រឹកគគ្រេងច្រើនឡើងនៅព្រឹកថ្ងៃទី១៨ សីហា ដោយបានប្រមូលផ្តុំគ្នានៅមុខសាលាខេត្ត ធ្វើការតវ៉ា សូមឱ្យអាជ្ញាធរខេត្តដោះស្រាយ និងជួយសំរួលដល់ការបង់ពន្ធម៉ូតូដែលមានតំលៃខ្ពស់ ហើយ ពួកគាត់គ្មានលទ្ធភាពក្នុងការបង់ពន្ធ ។

អ្នករត់ម៉ូតូឌុបម្នាក់បាននិយាយថា ចំពោះការជិះម៉ូតូដង្ហែជាក្បួននេះគឺពួកគាត់ពុំចង់ធ្វើទេ តែដើម្បីបង្ហាញឱ្យឃើញនូវភាពខ្វះខាតរបស់ពួកគាត់ក្នុងការបង់ពន្ធ ទើបពួកគាត់ធ្វើ ហើយការតវ៉ានេះគ្មានគោលបំណងអ្វីក្រៅពីសុំឱ្យអាជ្ញាធរជួយអន្តរាគមន៍ ក្នុងការបង់ពន្ធឱ្យមានតំលៃទាបនោះឡើយ។ ជាមួយគ្នានេះក៏មានការសុំឱ្យសមត្ថកិច្ចតាមគោលដៅ ដែលជាអ្នករឹតបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោកកុំប្រើអំពើហិង្សា កុំឱ្យទទួលលុយហើយចេញប័ណ្ណពិន័យ។ ម្យ៉ាងទៀតក៏មានការទាមទារឱ្យសមត្ថកិច្ចប៉ូលិសចរាចរ ជួយដោះស្រាយចំពោះម៉ូតូដែលបានចាប់ឃាត់ទុកកន្លងមកប្រគល់ឱ្យពួកគាត់វិញ ហើយ

បើនៅតែពុំព្រមធ្វើការដោះស្រាយឱ្យទេ ពួកគាត់ខ្លះច្បាស់ជាដាច់បាយពុំខានឡើយ ។ សំរាប់ពួកគាត់ដែលមានមុខរបររត់ម៉ូតូឌុប ពុំមានលុយច្រើននោះទេ មានអ្នកខ្លះចងការលុយគេមកទិញម៉ូតូមានតំលៃថោក សំរាប់ជាមធ្យោបាយរកកំរៃចិញ្ចឹមគ្រួសារ តែដល់ពេលសមត្ថកិច្ចឃាត់ម៉ូតូទុក ការរកចំណូលសំរាប់គ្រួសារ ទាំងការសន្សំទុកសងគេវិញ ក៏ត្រូវបញ្ចប់ តើពួកគាត់នឹងមានរឿងអ្វីកើតឡើង បើស្ថិតក្នុងស្ថានភាពបែបនេះ? ។

ឆ្លងតាមការចរចារវាងតំណាង៨រូប និងលោកអភិបាលខេត្តអស់រយៈពេលជិត២ម៉ោងរួចមក ដំណោះស្រាយ បណ្តោះអាសន្នមួយ ត្រូវបានតំណាងទាំង៨រូបទទួលយក ហើយបានធ្វើការរំសាយទៅកាន់លំនៅឋានវិញរៀង១ខ្លួន។ តាមអ្នកតំណាងម្នាក់បានឱ្យដឹងថា ដំណោះស្រាយដែលខាងសាលាខេត្តដាក់មក គឺជាបណ្តោះអាសន្ន ម៉ូតូអត់ស្លាកលេខពុំត្រូវបានចាប់ទេ ហើយបើចាប់ គឺមិនមានពាក់មួកសុវត្ថិភាព និងកញ្ចក់មើលក្រោយ ឯចំពោះម៉ូតូដែលចាប់រួចហើយ នឹងធ្វើការដោះស្រាយនៅថ្ងៃសុក្រខាងមុខ។ ចំពោះតំលៃពន្ធ សាលាខេត្តកំពុងប្រជុំគណៈបញ្ជាការឯកភាពធ្វើសំណើទៅរាជរដ្ឋាភិបាលជួយសំរួលដល់បងប្អូនប្រជាពលរដ្ឋ។ ក្រុមអ្នករត់ម៉ូតូឌុបបានសំដែងនូវក្តីសង្ឃឹមថា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នឹងជួយសំរួលដល់ពួក គាត់ជាក់ជាពុំខានឡើយ ព្រោះសម្តេចតែងតែមានប្រសាសន៍ថា "គ្មាននរណាម្នាក់យល់ចិត្តអ្នកក្រជាងរូបសម្តេចឡើយ" ។



ក្រុមអ្នករត់ម៉ូតូឌុបរាប់រយនាក់នៅមុខសាលាខេត្ត (រូបថត តាសោម )

ទាក់ទិននឹងការតវ៉ារបស់បងប្អូនប្រជាពលរដ្ឋនេះលោក ស្បោង សារ៉ាត អភិបាលខេត្តព្រះសីហនុ បានឱ្យដឹងថានៅក្នុងយុទ្ធនាការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មី គណៈអភិបាលបានយកចិត្តទុកដាក់ចំពោះទុក្ខលំបាករបស់ប្រជាពលរដ្ឋណាស់ ហើយជាក់ស្តែងនៅព្រឹកថ្ងៃទី១៧ សីហា គណៈបញ្ជាការឯកភាពធ្វើការប្រជុំពិភាក្សាជាមួយមន្ត្រីគយ លើការសុំបញ្ចុះតំលៃពន្ធជូនប្រជាពលរដ្ឋមួយចំនួនរួចហើយ និងកំពុងធ្វើសំណើទៅរាជរដ្ឋាភិបាល បន្តទៀត តាមការស្នើសុំរបស់បងប្អូនប្រជាពលរដ្ឋនៅខេត្តព្រះសីហនុ ។

បញ្ហាអំពាវនាវឱ្យមានការបញ្ចុះថ្លៃពន្ធនេះ មិនមែនតែនៅខេត្តព្រះសីហនុនោះទេ តែអាចមាននៅគ្រប់កន្លែងពិសេសនៅតាមតំបន់ជាយដែន ដែលមានការធូររលុងកន្លងមកបានធ្វើឱ្យមានបញ្ហានាពេលនេះ ។

នៅខេត្តស្វាយរៀង មិនមែនតែតំលៃកំណត់ឱ្យបង់ពន្ធប៉ុណ្ណោះទេ អ្នកមានពន្ធនាំចូលរួចហើយ បានរអ៊ូរទាំថាការធ្វើស្លាកលេខយកថ្លៃខុសគ្នាពីនៅភ្នំពេញ ដែលគយពិនិត្យ និងបញ្ជាក់លើលិខិតនាំចូលយកតំលៃ៥.០០០ រៀលក្នុងម៉ូតូ១គ្រឿង ការធ្វើស្លាកលេខ តំលៃ៤៦.០០០រៀល បើចង់ប្រញាប់ធ្វើភ្លាមយកភ្លាម តំលៃតាមការយល់ព្រមរីឯនៅស្វាយរៀងតំលៃធ្វើស្លាកលេខម៉ូតូ១គ្រឿង ពី២៨ដុល្លារទៅ៣០ដុល្លារ ទើបមន្ត្រីរាជការ និងប្រជាពលរដ្ឋក្រីក្រមិនព្រមធ្វើ ។ បច្ចុប្បន្នមានយុទ្ធនាការមន្ត្រីគយចាប់ឱ្យបង់ពន្ធនាំចូលទៀត ពិតជាមានបញ្ហាកាន់តែធ្ងន់ធ្ងរ មានផាកពិន័យពីការអត់ពាក់មួកសុវត្ថិភាព អត់កញ្ចក់មើលក្រោយ ពន្ធផ្លូវ ស្លាកលេខ និងពន្ធនាំចូល ហើយអ្វីដែលមន្ត្រីរាជការ និងប្រជាពលរដ្ឋភ័យ និងព្រួយបារម្ភខ្លាំងនោះ គឺពន្ធនាំចូល ។

ទាក់ទិននឹងយុទ្ធនាការនេះ លោកសំ ប៊ុណ្ណារិន អភិបាលរងខេត្តប្រធានគណៈកម្មាធិការសុវត្ថិភាពចរាចរណ៍ផ្លូវគោកខេត្ត និងជាអនុប្រធានគណៈបញ្ជាការដឹកនាំត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកខេត្ត បានមានប្រសាសន៍ថា លោកទទួលស្គាល់ថា ការអនុវត្តន៍ច្បាប់ គឺតែងតែប៉ះពាល់ទៅនឹងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ហើយ ក៏ប៉ុន្តែដើម្បីសុវត្ថិភាព សន្តិសុខសង្គម បង្ក្រាបការនាំចូលគេចពន្ធ ដើម្បីធានាសុវត្ថិភាពទប់ស្កាត់អំពើចោរកម្ម យើងត្រូវតែអនុវត្តច្បាប់ ហើយក៏យើងមិនតឹងរ៉ឹងអ្វីដែរ រាជរដ្ឋាភិបាលតែងតែអនុគ្រោះ ។ លោកនឹងពិនិត្យមើលលើបញ្ជីតារាងតំលៃការបង់ពន្ធនាំចូលម៉ូតូនេះសិន លទ្ធផលយ៉ាងណាលោកនឹងជំរាបជូនតាមក្រោយ ។



ការជិះម៉ូតូដង្ហែក្បួនតាមផ្លូវក្រុងព្រះសីហនុ

ចំពោះប្រជាពលរដ្ឋ មន្ត្រីរាជការខេត្តស្វាយរៀងទាំងអស់ បានសំណូមពរមកកោះសន្តិភាពមេត្តាចុះផ្សាយ សុំអំពាវនាវដល់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន មេត្តាអនុគ្រោះបញ្ចុះតំលៃសេវាបង់ពន្ធនាំចូលនូវម៉ូតូគ្រប់ប្រភេទឱ្យមានតំលៃថោកសមរម្យ ដោយសារនៅរដូវវស្សានេះ ប្រជាពលរដ្ឋជួបគ្រោះធម្មជាតិរាំងស្ងួត សំណាបសន្ទូងឆេះខ្លោចងាប់អស់ ប្រេងឡើងថ្លៃ ប្រជាពលរដ្ឋកំពុងជួបវិបត្តិស្បៀងអហារប្រចាំថ្ងៃ តើមានប្រាក់ឯណាសំរាប់ទៅបង់ពន្ធតាមតំលៃសេវារបស់មន្ត្រីគយនោះ ហើយបើដាក់កំលាំងនគរបាល កងរាជអាវុធហត្ថយាមស្ទាក់ចាប់គ្រប់ច្រកផ្លូវនោះតើប្រជាពលរដ្ឋក្រីក្រណាម្នាក់ហ៊ានចេញម៉ូតូទៅរកស៊ី? ពិតជាអត់បាយកូនស្លាប់មិនខានទេ ។ ដូច្នេះសូមមេត្តាបញ្ចុះតំលៃការធ្វើស្លាកលេខ និងការបង់ពន្ធនាំចូលនេះផង ។